លេខ ១៦៩ ថ្ងៃអង្គារ ទី១៣ ខែកញ្ញា ឆ្នាំ២០០៥

ពត៌មានក្នុងប្រទេស

# ព្រះមហាក្សត្រ ៖ "ព្រះពុទ្ធសាសនាបានផ្តល់ដល់សង្គមកម្ពុជានូវវប្បធម៌សន្តិភាព"

*លោក ជឹម ណារី AKP ភ្នំពេញ*

ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បានមានព្រះរាជបន្ទូលថា ៖ ព្រះពុទ្ធសាសនាបានផ្តល់ដល់សង្គមកម្ពុជានូវវប្បធម៌សន្តិភាព ហើយប្រជាពលរដ្ឋបាន និងកំពុងតែខិតខំពង្រឹងវប្បធម៌ដ៏ឧត្តុង្គឧត្តមនេះឱ្យក្លាយទៅជាសីលធម៌សង្គមដែលជាបែបផែននៃការរស់នៅរបស់ប្រជារាស្ត្រកម្ពុជាគ្រប់រូប ។

ព្រះរាជបន្ទូលដូច្នេះ ត្រូវបានព្រះករុណាធ្វើឡើងនៅក្នុងព្រះរាជពិធីបើកអនុសំវច្ឆរៈ មហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី១៤ នាព្រឹកថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៥ នៅសាលសន្និសីទចតុមុខ ។

យាង និងអញ្ជើញចូលរួមក្នុងពិធីនោះដែរ ក៏មានវត្តមានសម្តេច ជីវ៉ន មុនីរក្ស អនុប្រធានទី១ ព្រឹទ្ធសភា សម្តេច ហេង សំរិន ប្រធានរដ្ឋសភាស្តីទី ឯ.ឧ ស ខេង នាយករដ្ឋមន្ត្រីស្តីទី ព្រមទាំងតំណាង ឯ.ឧ លោកជំទាវ ជាសមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងមន្ត្រីសង្ឃ ដូនជី តាជី មកពីបណ្តាខេត្ត-ក្រុងទូទាំងប្រទេសយ៉ាងច្រើនកុះករ ។

ព្រះករុណា មានព្រះរាជបន្ទូលបន្តថា ៖ បច្ចុប្បន្នប្រទេសជាតិយើងកំពុងមានស្ថេរភាព មានសន្តិភាពដ៏ពេញលេញ និងកំពុងឈានឡើងលើមាគ៌ាអភិវឌ្ឍន៍ ប្រកបដោយកិត្យានុភាពដ៏សក្តិសមនៅក្នុងក្របខ័ណ្ឌតំបន់ និងនៅលើឆាកអន្តរជាតិ ។ រាជរដ្ឋាភិបាលកម្ពុជាកំពុងខិតខំបន្តការកសាងជាតិលើគ្រប់វិស័យ ពិសេសកំពុងដំណើរការកែទម្រង់ដ៏ទូលំទូលាយ និងជ្រាលជ្រៅ ។ រីឯអង្គការនិតិប្បញ្ញត្តិក៏បានខិតខំប្រឹងប្រែងរួមសហការយ៉ាងសកម្មក្នុងការកសាងច្បាប់ សំដៅលើកកំពស់ការគ្រប់គ្រងរដ្ឋ គ្រប់គ្រងសង្គម គ្រប់គ្រងសេដ្ឋកិច្ចឱ្យកាន់តែល្អប្រសើរ ស្អាតស្អំ មានប្រសិទ្ធភាព និងតម្លាភាព ។

ព្រះអង្គបានមានព្រះរាជបន្ទូលសង្កត់ធ្ងន់ថា ៖ ឈរលើស្មារតីនេះ អនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី១៤ ពិតជានឹងបានផ្តល់នូវវិភាគទានយ៉ាងសំខាន់ដល់ការប្រព្រឹត្តទៅ និងសង្គមជាតិក្នុងការអំពាវនាវព្រះសង្ឃគ្រប់លំដាប់ថ្នាក់ និងមហាជនគ្រប់ស្រទាប់ គ្រប់និន្នាការនយោបាយ និងសូមពិចារណានូវគ្រោះថ្នាក់អំពីអំណាច នៃ លោភៈ ទោសៈ មោហៈ ដែលជាឫសគល់នៃអកុសលកម្មទាំងឡាយ និងគួរជៀសវាង ហើយងាកមកប្រតិបត្តិតាមផ្លូវអហិង្សា ការមិនចងគំនុំគុំគួនព្យាបាទ និងការគោរពស្រឡាញ់សុខសន្តិភាពរវាងគ្នានឹងគ្នាតាមការប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ទូល

ព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំសង្ឃឹម និងជឿជាក់ថា ក្រោមម្លប់ដ៏ត្រជាក់ត្រជុំនៃព្រះធម៌របស់ព្រះពុទ្ធជាអម្ចាស់ និងលើមូលដ្ឋាននៃមហាសាមគ្គីជាតិ ឯកភាពជាតិ សង្គមកម្ពុជាយើងទាំងមូលពិតជានឹងទទួលបាននូវជោគជ័យធំៗថែមទៀតក្នុងការកសាងប្រទេសជាតិ កសាងព្រះពុទ្ធសាសនា និងជីវភាពរស់នៅរបស់ប្រជារាស្ត្រយើងឱ្យកាន់តែចំរុងចំរើនឡើង កាត់បន្ថយបាននូវភាពក្រីក្រជាជំហានៗ ។ ទទួលបានជោគជ័យទាំងនេះ អាស្រ័យដោយប្រជាពលរដ្ឋយើងចេះរួបរួមគ្នា សាមគ្គីគ្នា ចេះយោគយល់គ្នា ចេះសណ្តោសប្រណីគ្នា មានសច្ចៈភាព ស្មោះត្រង់ មានខន្តី អត់ធ្មត់ តស៊ូ មានការគោរពដឹងគុណ និងមានព្រហ្មវិហារធម៌ទៅវិញទៅមក ក្រោមពន្លឺព្រះធម៌ដ៏ថ្លៃថ្លា និងតាមកម្មវិធីនយោបាយដ៏សមស្របរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ព្រះករុណា ព្រះមហាក្សត្រ បានមានព្រះរាជបន្ទូលបន្ថែមទៀតថា មានបញ្ហាមួយចំនួនដែលអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី១៤ នឹងលើកយកមកធ្វើជាប្រធានបទ ដើម្បីពិភាក្សាស្វែងរកគន្លឹះដោះស្រាយ និងកែលំអសមស្រប កាន់តែមានប្រសិទ្ធភាព និងមានភាពយុត្តិធម៌ទៅតាមគោលការណ៍រួមនៃព្រះពុទ្ធសាសនា ។ ការរំងាប់ទំនាស់អធិករណ៍ទាំងឡាយក្នុងសាសនា ដែលបុគ្គលបានបង្កឡើង ក៏ត្រូវតែថ្លឹងថ្លែងពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើព្រះធម៌វិន័យរបស់ព្រះពុទ្ធបរមគ្រូជាអម្ចាស់មកធ្វើជាត្រីវិស័យ ។ ព្រះពុទ្ធសាសនា គឺជាសាសនារបស់រដ្ឋ មានតួនាទីជាគំរូនៃភាពសុខដុមរមនា ប្រកបដោយផែនឯកភាពរឹងមាំ ជៀសវាងប្រកាន់បក្សពួកដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសជាតិ និងសាសនា ។

ព្រះមហាក្សត្របានអំពាវនាវឱ្យគ្រប់សាសនាទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា មេត្តាចូលរួមសហការគ្នាល្អ រួមរស់ដោយសេចក្តីសុខក្សេមក្សាន្ត ដើម្បីទ្រទ្រង់សង្គមជាតិកម្ពុជាទាំងមូលមានស្ថេរភាព និងការអភិវឌ្ឍន៍ជាគុណប្រយោជន៍រួម ស្របទៅនឹងបាវចនានៃព្រះរាជាណាចក្រកម្ពុជាយើងគឺ ជាតិ សាសនា ព្រះមហាក្សត្រ ។

ក្នុងឱកាសយាងចូលរួមក្នុងអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី១៤ នេះ ព្រះករុណាព្រះមហាក្សត្រក៏បានប្រោសព្រះរាជទានថវិកាចំនួន ៩.000ដុល្លារអាមេរិកដល់ព្រះរាជពិធីនេះ ព្រមទាំងព្រះរាជទាននូវថវិកា និងសម្ភារៈមួយចំនួនប្រគេនព្រះសង្ឃ ដូនជី តាជី ក្នុងឱកាសនោះផងដែរ ។/

## កម្ពុជាមានព្រះសង្ឃចំនួន ៥៩.៧៣៨អង្គ និងមានវត្ត ៤.0៦0

*លោក ជឹម ណារី AKP ភ្នំពេញ*

នៅក្នុងឱកាសបើកអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃលើកទី១៤ ថ្ងៃទី១២ កញ្ញា ២00៥ នៅសាលចតុមុខ ឯ.ឧ យុន ហាំង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា បានធ្វើរបាយការណ៍

ទូលថ្វាយព្រះមហាក្សត្រ ប្រគេនព្រះសង្ឃ និងជំរាបសន្និបាតថា ៖

រាល់អនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃ សម្ដេចឪ សម្ដេចម៉ែ ព្រះអង្គតែងតែសព្វព្រះរាជហឫទ័យប្រោសប្រទានឱវាទល្អៗ នឹងព្រះអង្គតែងតែជួយឧបត្ថម្ភបរិច្ចាក នូវព្រះរាជទ្រព្យផ្ទាល់សំរាប់អនុវត្តអនុសំវច្ឆរៈមហាសន្និបាតដើម្បីដំណើរការបានល្អ ប្រកបដោយជោគជ័យបាន ១៤លើកមកហើយ រហូតមកដល់ពេលនេះ ។ ឯព្រះសង្ឃ និងវត្តអារាមក៏មានការរីកចំរើនទាំង ២គណៈ ដែលនៅពេលនេះ មានវត្ត ៤.០៦០ និងព្រះសង្ឃចំនួន ៥៩.៧៣៨អង្គ ។

ឯកឧត្ដម យុន ហាំង គូសបញ្ជាក់ថា ៖ អប់រំក្នុងប្រព័ន្ធយើងមានសាលាពុទ្ធិកបឋមសិក្សាមាន ៥៥៥សាលា មានសមណសិស្សចំនួន ១៤.៤៩២អង្គ ។

-ពុទ្ធិកមធ្យមសិក្សាទាំងពីរកំរិតមាន ២៦សាលា គឺនៅភ្នំពេញ ៧សាលា នៅតាមខេត្តមាន ១៩ សាលា មានសមណសិស្សចំនួន ៤.៣១៨អង្គ ។

-ពុទ្ធិកមហាវិទ្យាល័យមាន ១កន្លែង នៅភ្នំពេញ គឺពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ មានសមណនិស្សិត ២៦៥រូប សិក្សាស្រាវជ្រាវថ្នាក់បរិញ្ញាបត្រ ចែកជា ២ដេប៉ាតឺម៉ង់ គឺវិទ្យាសាស្ត្រអប់រំ និងទស្សនវិជ្ជាព្រះពុទ្ធសាសនា ។

គន្លងមក មានសមណនិស្សិត ៤៤រូប ក្នុងនោះមាននិស្សិតស្រីម្នាក់ មានចំនួន ២វគ្គ បានបញ្ចប់បរិញ្ញាបត្រផ្នែកទស្សនវិជ្ជាពុទ្ធសាសនា ហើយពិធីចែកសញ្ញាបត្រនេះ ប្រារព្ធឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

សាលាធម្មវិន័យ ដែលជាមូលដ្ឋានគ្រឹះសំរាប់សមណសិស្សបន្តវិជ្ជាទៅពុទ្ធិកបឋមសិក្សា គ្រប់គ្រងដោយវត្តផ្ទាល់ មាន ៧៦៨សាលា និងមានសមណសិស្ស ១៥.៨៣៦អង្គ កំពុងសិក្សា ។

ទន្ទឹមនឹងការពង្រឹងផ្នែកពុទ្ធិកសិក្សា ផ្នែកវិបស្សនាធុរៈ ក៏ត្រូវបានពង្រឹងនៅតាមខេត្ត-ក្រុងមួយចំនួនសំដៅជួយតំរង់ស្មារតីពុទ្ធសាសនិកអោយគោរពតាមពុទ្ធឱវាទរបស់ព្រះពុទ្ធជាអម្ចាស់ ។

អំពីការអប់រំសីលធម៌ ឯ.ឧ យុន ហាំង ថ្លែងថា ៖ ការអប់រំក្រៅប្រព័ន្ធមានកម្មវិធីនមស្សការព្រះរតនៈត្រៃ សមាទានសីលរៀងរាល់ព្រឹក ការផ្សព្វផ្សាយធម្មទេសនារៀងរាល់ថ្ងៃសីល និងពិធីបុណ្យប្រពៃណីធំៗ កម្មវិធីសន្ទនាធម៌ ធម្មសាកច្ឆតាមវិទ្យុ ទូរទស្សន៍ឯកជនខ្លះៗរៀងរាល់ថ្ងៃ ការរៀនសូត្រអប់រំផ្លូវចិត្តរៀងរាល់ថ្ងៃ សៅរ៍-អាទិត្យ នៅតាមបណ្ដាវត្តមួយចំនួននៅភ្នំពេញ នៅតាមខេត្ត និងតាមមណ្ឌលវិបស្សនានានាក្នុងព្រះរាជាណាចក្រកម្ពុជាបានរួមចំណែកដល់ការលើកស្ទួយស្មារតី សីលធម៌ ចរិយាធម៌ សច្ចធម៌ ដែលជាវប្បធម៌ប្រពៃណីល្អផូរផង់របស់ជាតិយើង ដើម្បីពង្រឹងសន្តិភាពអហឹង្សា និងការអភិវឌ្ឍន៍សង្គម ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានធ្វើការស្រាវជ្រាវអំពីក្បួនទស្សន៍ទាយ និងពន្យល់ពាក្យហោរាសាស្ត្រ អំពីការប្រើ និងបកស្រាយការប្រើពុទ្ធសករាជនៅប្រទេសកម្ពុជា សិក្សាស្រាវជ្រាវចងក្រងរឿងព្រេងខ្មែរ ការបន្ត និងការផ្លាស់ប្តូរបកប្រែអដ្ឋកថា ធម្មបទពីបាលីមកខ្មែរ ការបង្រៀនធម៌រៀងរាល់ថ្ងៃច័ន្ទ ធ្វើបទានុក្រម ធម្មបទ ។ល។ ការទទួលអ្នកអាន និងស្រាវជ្រាវនៅបណ្ណាល័យចំនួន ១០.៥៥៣ នាក់ ពង្រឹងការងារបណ្ណាល័យនៅខេត្តព្រៃវែង ខេត្តស្វាយរៀង ដោយបង្រៀនផ្នែកបច្ចេកទេសបណ្ណាល័យ បង្កើត Website សំរាប់អ្នកចូលចិត្តស្រាវជ្រាវ ។ ចែកផ្សាយសៀវភៅវាមយណៈបទានុក្រមដល់ឥស្សរជន និងបណ្ណាល័យមួយចំនួនក្នុងព្រះរាជាណាចក្រកម្ពុជា ។

ចំណែកឯការបោះពុម្ព មានពុទ្ធសាសនិកជនដទៃទៀត បានធ្វើការស្រាវជ្រាវបោះពុម្ពសៀវភៅធម៌អប់រំខ្នាតតូច អត្ថបទខ្លីៗ ស្រួលយល់ ងាយចងចាំ សំរាប់អប់រំដល់ពុទ្ធសានិកជនទូទៅផងដែរ ។

អង្គអនុសំវច្ឆរៈមហាសន្និបាតនឹងពិភាក្សារកគន្លឹះសំខាន់ៗ សំរាប់កែសំរួលក្នុនន័យលើកស្ទួយវិស័យព្រះពុទ្ធសាសនា ចងក្រងបន្ថែមក្នុងសង្ឃប្រកាសទាំងពីរគណៈ សំរាប់ធ្វើការផ្សព្វផ្សាយជាសាធារណៈ និងសំរាប់ប្រតិបត្តិការឱ្យបានខ្ជាប់ខ្ជួននៅគ្រប់វត្តអារាម និងព្រះសង្ឃទូទាំងប្រទេស ។/

## ក្រុមនិស្សិតជប៉ុន និងកម្ពុជា ចុះស្រាវជ្រាវការងារកសិកម្មនៅខេត្តតាកែវ

*លោក ប៉ាល់ សុង AKP ភ្នំពេញ*

ឯកឧត្តម ស៊្វូ ភីរិន្ទ អភិបាលខេត្តតាកែវបានមានប្រសាសន៍ថា ខេត្តតាកែវថ្វីត្បិតតែការអភិវឌ្ឍន៍លើគ្រប់វិស័យនៅមានកំរិត ប៉ុន្តែក៏មានវិស័យកសិកម្មមួយដែរដែលកំពុងអភិវឌ្ឍន៍គួរឱ្យមោទនៈបំផុតដែលសព្វថ្ងៃនេះកំពុងតែក្លាយជាតំបន់គំរូខាងការងារបង្កបង្កើនផលស្រូវ សំរាប់ទូទាំងប្រទេសមកដកយកបទពិសោធន៍ពីខេត្តតាកែវទៅអនុវត្តទៀតផង ។

ឯកឧត្តម អភិបាលខេត្ត សំដែងមោទនភាពនេះនៅក្នុងឱកាសសំណេះសំណាលមួយជាមួយក្រុមនិស្សិតសាកលវិទ្យាល័យណាហ្គោយ៉ា ប្រទេសជប៉ុន និងក្រុមនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ កាលពីចុងសប្តាហ៍នេះ ដែលបានចុះស្រាវជ្រាវ និងស្វែងយល់បញ្ហាមួយចំនួននៅខេត្តតាកែវកាលពីចុងសប្តាហ៍មុននេះ ។ ឯកឧត្តម អភិបាលខេត្ត ក៏បានប្រាប់ក្រុមនិស្សិតទាំងពីរក្រុមនោះផងដែរ អំពីការវិវត្តន៍លើវិស័យកសិកម្មដែលក្នុងរដូវប្រាំងកន្លងមកនេះ ដោយមានការយកចិត្តទុកដាក់ពីក្រសួងកសិកម្មផ្ទាល់ផង ប្រជាពលរដ្ឋទូទាំងខេត្តបានធ្វើស្រែប្រាំងលើសផែនការ គឺអនុវត្តបាន៦៧.០០០ហិកតា លើផែនការ ៦០.០០០ ហិកតា ក្នុងនោះភាគច្រើនធ្វើតាមប្រពលវប្បកម្ម ហើយទទួលបានទិន្នផលខ្ពស់ទៀតផង ។

ឆ្លងតាមការរីកចំរើននេះ ឯកឧត្តម អភិបាលខេត្តក៏បានថ្លែងអំណរគុណផងដែរ តាមរយៈលោកសាស្ត្រាចារ្យ និងក្រុមនិស្សិតសាកលវិទ្យាល័យណាហ្គោណាយ៉ាចំពោះរដ្ឋាភិបាលប្រទេសជប៉ុនដែលបានជួយ

កម្ពុជាលើគ្រប់វិស័យ ជាពិសេសលើវិស័យកសិកម្ម ដែលអាចធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាទទួលបាននូវបច្ចេកទេសកសិកម្មថ្មីជាបណ្តើរ១ និងមានស្បៀងអាហារគ្រប់គ្រាន់ ។

ក្រុមនិស្សិតសាកលវិទ្យាល័យណាហ្គោយ៉ា ជប៉ុន សហការជាមួយក្រុមនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានចុះធ្វើការសិក្សាស្រាវជ្រាវស្វែងយល់រយៈពេល ១៣ថ្ងៃ លើវិស័យសំខាន់ៗចំនួន ៤ គឺកសិកម្ម អភិវឌ្ឍន៍ជនបទ ការងារវប្បធម៌សាសនា ការងារអប់រំក្នុងទឹកដីខេត្តតាកែវ ហើយក្រុមនិស្សិតទាំងពីរបានចូលជួបសំណេះសំណាលជាមួយអាជ្ញាធរខេត្តនៅសាលមហោស្រពខេត្តតាកែវ កាលពីយប់ថ្ងៃទី០៩ ខែកញ្ញា ២០០៥ ។/

## ខេត្តកំពង់ស្ពឺបង្កើតគណៈកម្មការចុះវាស់វែងដី ២០០ហិកតា បែងចែកជូនប្រជាពលរដ្ឋនៅភូមិចំការចេក

*លោក លឹម សាន្ត AKP កំពង់ស្ពឺ*

ផ្ទៃដីចំនួន ២០០ហិកតា ដែលលោកជំទាវ យូ អយ បានសន្យាប្រគល់ជូនប្រជាពលរដ្ឋនៅភូមិចំការចេក ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ តាំងតែពីឆ្នាំ២០០៤មកនោះ គិតមកដល់បច្ចុប្បន្ន ពុំទាន់បានបែងចែកជូនប្រជាពលរដ្ឋទាំងនោះនៅឡើយទេ ។

លោក វៀម ច័ន្ទមន្នី អភិបាលរងទី២ ខេត្តកំពង់ស្ពឺ បានឱ្យដឹងថា : ដីដែលលោកជំទាវ យូ អយ ធ្វើសម្បទានចំនួន ២០០ហិកតាទៅឱ្យប្រជាពលរដ្ឋក្នុងភូមិចំការចេក ដើម្បីប្រកបការងារធ្វើស្រែចំការចិញ្ចឹមជីវិតនោះ ត្រូវបានសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្វើចំណារប្រគល់អោយអាជ្ញាធរខេត្តកំពង់ស្ពឺ ជាអ្នកបែងចែក ក្នុងនោះក៏មានទាំងថ្លែងអំណរគុណចំពោះការធ្វើវិភាគទានរបស់លោកជំទាវ ចំពោះប្រជាពលរដ្ឋក្នុងតំបន់នេះផងដែរ ។ លោក វៀប ច័ន្ទមន្នី បានបន្តទៀតថា បន្ទាប់ពីបានទទួលនូវចំណាររបស់សម្តេចនាយករដ្ឋមន្ត្រី អាជ្ញាធរខេត្តកំពង់ស្ពឺក៏បានបង្កើតគណៈកម្មការបែងចែកដីនេះជូនប្រជាពលរដ្ឋនៅទីនេះភ្លាមៗដែរ ដោយមានរូបលោកជាប្រធាន ។ គណៈកម្មការនេះក៏បានចុះទៅធ្វើការដែរ ប៉ុន្តែនៅតែពុំទាន់សំរេចលទ្ធផលនៅឡើយ សូម្បីតែការចុះស្រង់ស្ថិតិប្រជាពលរដ្ឋនៅក្នុងតំបន់នោះ ក៏ពុំទទួលលទ្ធផលគ្រប់ជ្រុងជ្រោយផង បញ្ហាទាំងនេះដែលជាការលំបាកក្នុងការឈានទៅដោះស្រាយ ។

នៅដើមខែកញ្ញា ឆ្នាំ២០០៥នេះ គណៈកម្មការចំរុះក៏បានចុះទៅមូលដ្ឋាននោះ ដើម្បីធ្វើការវាស់វែងជាថ្មី គោលបំណងឈានទៅសំរេចលទ្ធផលចុងក្រោយ ប៉ុន្តែការសំរេចយ៉ាងណាពុំទាន់បានដឹងនៅឡើយទេ ។ លោក ទេព មាន អភិបាលស្រុកភ្នំស្រួច បានឱ្យដឹងថា បន្ទាប់ពីចុះស្រង់ស្ថិតិរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងដីលោកជំទាវ យូ អយ ភូមិចំការចេករួច គណៈកម្មការធ្វើការវាស់វែងដីជាក់ស្តែង

ចំនួន ២០០ហិកតា ដើម្បីឆ្លងគណៈកម្មការ រួចធ្វើការប្រជុំជាមួយប្រជាពលរដ្ឋនៅតំបន់នោះ រួចធ្វើការបែងចែកទៅតាមការជាក់ស្តែងនៃគ្រួសារដែលរស់នៅក្នុងតំបន់នោះ ។

ចំពោះប្រជាពលរដ្ឋនៅក្នុងតំបន់នោះវិញ ពួកគាត់បាននិយាយថា ពួកគាត់អត់ដីនៅ ទើបនាំគ្នាមកចាប់ដីតំបន់នេះដែលនៅទំនេរ ព្រោះពួកគាត់ចាត់ទុកវាជាដីរដ្ឋ បើឱ្យពួកគាត់ចេញ គឺមិនព្រមចេញជាដាច់ខាត ។ ប៉ុន្តែបើការបែងចែកដីរបស់លោកជំទាវ យូ អយ សមស្របអាចទទួលយកបាន ពួកគាត់ក៏យល់ព្រមដែរ យ៉ាងហោចណាស់ក្នុងមួយគ្រួសារ ១ហិកតា ដែរ ។

គួរបញ្ជាក់ថា ដីដែលត្រូវបែងចែកនេះ គឺជាដីរបស់លោកជំទាវ យូ អយ ដែលមានប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ ។ ប៉ុន្តែដោយពុំទាន់មានការអភិវឌ្ឍន៍ ប្រជាពលរដ្ឋដែលខ្វះដីចំការ ដីស្រែ ដែលមកពីតំបន់នានា បាននាំគ្នាមកហ៊ុំព័ទ្ធ បោះបង្គោលរបង សង់ជាកូនខ្ទម ឬផ្ទះតូចៗ និងដាំដំណាំសព្វបែបយ៉ាងដើម្បីយកដីទាំងនោះធ្វើជាកម្មសិទ្ធិ ហើយបញ្ហានះកើតមានទំនាស់ជាបន្តបន្ទាប់រវាងប្រជាពលរដ្ឋ និងម្ចាស់ដីស្របច្បាប់ រហូតមានបាតុកម្មតវ៉ាជាញឹកញាប់មកខេត្ត និងទៅដល់ប្រមុខរាជរដ្ឋាភិបាល រដ្ឋសភាជាតិដើម្បីឱ្យដោះស្រាយ ។/

## ក្រុងព្រះសីហនុលែងកូនគ្រែងឈាមជាង ២តោន នៅក្នុងសមុទ្រ

*លោក ព្រាក់ លាង AKP ក្រុងព្រះសីហនុ*

កាលពីសប្តាហ៍កន្លងទៅ មន្ទីរកសិកម្មក្រុងព្រះសីហនុបានលែងកូនគ្រែងឈាមជាង ២តោន ទៅក្នុងសមុទ្រវិញ ដើម្បីការពារការវិនាសហិនហោចនូវធនធានសមុទ្រ ។

លោក នៅ រតនា ប្រធានមន្ទីរកសិកម្ម បានបញ្ជាក់ថា : កូនគ្រែងឈាមជាង ២តោននេះ គឺមន្ត្រីជលផលចាប់បានពីទូកនេសាទតូចៗនៅតំបន់កោះខ្យង សង្កាត់អូរជ្រៅ ខណ្ឌព្រៃនប់ ដែលលបលួចអូសយកកូនគ្រែងឈាមតូចៗនេះ ទៅលក់នៅប្រទេសវៀតណាម ព្រោះនៅកម្ពុជាពុំទាន់មានទីផ្សារទេ ហើយច្បាប់បានហាមឃាត់ជាដាច់ខាត ការនេសាទកូនគ្រែងឈាមតូចៗទាំងនេះ ព្រោះវាបានបំផ្លាញធនធានសមុទ្ររបស់យើង ។ លោក រតនា ក៏បានបញ្ជាក់ទៀតថា : ច្បាប់ពុំបានហាមឃាត់ការធ្វើនេសាទនូវប្រភេទគ្រែងឈាមធំៗនោះទេ ។ មន្ត្រីជលផលមួយរូបបានប្រាប់ឱ្យដឹងថា: ជារឿយៗទូកនេសាទតូចៗតែងលបលួចនេសាទកូនគ្រែងឈាមតូចៗនេះនៅតំបន់កោះធ្យូង ដែលនៅទីនោះ កូនគ្រែងឈាមតូចៗសំបូរណាស់ ព្រោះវាទើបនឹងរីកចំរើនកកើតថ្មី ហើយក្រុមរបស់លោកក៏បានចូលរួមទប់ស្កាត់ជាប្រចាំនូវបទល្មើសនេសាទក្នុងតំបន់នោះដែរ ព្រោះថា តំបន់កោះខ្យងកំពុងតែអភិរក្សនូវគ្រប់ធនធានសមុទ្រទាំងអស់

អាចនិយាយបានថា ជាតំបន់ដែលរដ្ឋបានហាមឃាត់ការធ្វើនេសាទគ្រប់ប្រភេទ ដើម្បីការពារតំបន់នោះសម្រាប់ការរីកធំធាត់គ្រប់ធនធានសមុទ្រទាំងអស់ ។

មន្ត្រីជំនាញជលផលក្រុងក៏បានបញ្ជាក់ដែរថា : កូនគ្រែងឈាមនេះក្នុងមួយគីឡូក្រាមវាមានចំនួនពី ៥.០០០ ទៅ ៧.០០០កូន ឯណោះ ដូចនេះជាប្រកាសមួយដែលគួរតែត្រូវយកចិត្តទុកដាក់ ព្រោះវាបានបំផ្លាញធនធានសមុទ្ររបស់យើងយ៉ាងខ្លាំងបំផុត ។

លោក នៅ រតនា បានបញ្ជាក់ដែរថា: បញ្ហានេះ ផ្នែកជំនាញជលផលមិនបានធ្វេសប្រហែសទេ ជាពិសេសគឺតំបន់កោះខ្យងដែលជាភូមិសាស្ត្រអំណោយផលដល់ពួកនេសាទ ដែលតែងតែចូលលួចនេសាទ ហើយយកទៅលក់នៅប្រទេសវៀតណាមតែម្តង ព្រោះតំបន់នោះ មានភូមិសាស្ត្រជាប់ជាមួយប្រទេសវៀតណាម ។ គួររំលឹកដែរថា ក្រៅពីកូនគ្រែងឈាមតូចៗ ច្បាប់ក៏បានហាមឃាត់ផងដែរការនេសាទកូនក្តាមតូចៗ ។/

## នាវាហ្វ្រីកហ្គីនកងកម្លាំងស្វ័យត្រាណជប៉ុនបានបញ្ចប់ទស្សនកិច្ចនៅកម្ពុជា

*លោក ង៉ូ សុមុនី AKP ក្រុងព្រះសីហនុ*

នាវាហ្វ្រីកហ្គីនរបស់កងកម្លាំងស្វ័យត្រាណជើងទឹកជប៉ុនចំនួន ០៣គ្រឿង បានចេញទៅវិញហើយកាលពីថ្ងៃទី០៩ កញ្ញា បន្ទាប់ពីបានចូលចតកំពង់ផែសមុទ្រ ក្រុងព្រះសីហនុ កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០០៩ ដើម្បីពង្រឹង និងពង្រីកទស្សនៈវិស័យជាលក្ខណៈអន្តរជាតិ ។

លោក រស់ វាសនា មេបញ្ជាការរងកងទ័ពជើងទឹកមូលដ្ឋានសមុទ្ររាម បានមានប្រសាសន៍ឱ្យដឹងថា : នេះជាលើកទី១ ដែលកងនាវាស្វ័យត្រាណជើងទឹកជប៉ុន ០៣គ្រឿង ចូលមកឈប់សំចតនៅលើទឹកដីកម្ពុជា ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែល្អ ដើម្បីការពារសន្តិសុខក្នុងដែនសមុទ្រ ព្រមទាំងការពារផលប្រយោជន៍របស់ប្រទេស ។ ក្នុងការស្នាក់នៅរបស់នាវាទាំង ០៣គ្រឿង ក៏បានអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលទស្សនាអំពីលក្ខណៈបច្ចេកទេស គ្រឿងសព្វាវុធនៅក្នុងនាវាទាំង៣គ្រឿងនេះផងដែរ។

ក្នុងឱកាសនេះ ឯកឧត្តមនាវីទោ ណាស៊ី ណាតាស៊ីរ៉ូ ស៊ីបាតា មេបញ្ជាការនាវាហ្វ្រីកហ្គីននៃកងកម្លាំងស្វ័យត្រាណជើងទឹកជប៉ុនឱ្យដឹងថា លោកមានមោទនភាពចំពោះការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់កងទ័ពជើងទឹកកម្ពុជា ហើយនេះជាលើកទីមួយដែលកងនាវាហ្វ្រីកហ្គីនជប៉ុនបានឈប់សំចតនៅព្រះរាជាណាចក្រកម្ពុជា ។ គណៈប្រតិភូរបស់លោកបានចូលបង្គំគាល់ព្រះមហាក្សត្រកម្ពុជា បានចូលជួបសវនាការជាមួយរដ្ឋមន្ត្រីការពារប្រទេសកម្ពុជា ជួប ឯកឧត្តម អភិបាលក្រុងព្រះសីហនុ និងបានទស្សនាកន្លែងសំខាន់របស់កម្ពុជា ។

នាវាទាំង ០៣គ្រឿង បានធ្វើដំណើរចេញទៅក្រៅប្រទេសជារៀងរាល់ឆ្នាំ ដើម្បីធ្វើការហ្វឹកហ្វឺន ការអភិវឌ្ឍន៍ជាអ្នកដឹកនាំជំនាញគ្រប់គ្រង និងបើកបរនាវារបស់នាយទាហានជំនាន់ថ្មីនៅលើសមុទ្រ ដើម្បីពង្រីកទស្សនៈវិស័យជាលក្ខណៈអន្តរជាតិ ជំរុញមិត្តភាពឱ្យកាន់តែប្រសើរឡើងជាមួយប្រទេសផ្សេងៗ នៃកងទ័ពជើងទឹកនៃបណ្តាប្រទេសដែលនាវាបានឈប់សំចត ។ កងនាវានេះបានចាកចេញពីប្រទេសរបស់ខ្លួន កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៩ ដោយធ្វើទស្សនកិច្ចប្រទេសមានដូចជា សហរដ្ឋអាមេរិក ម៉ិចស៊ិកកូ ចក្រភពអង់គ្លេស នរ៉ូវែស រុស្ស៊ី អាល្លឺម៉ង់ បារាំង ម៉ាល់តា ទួរគី អេហ្ស៊ីប និងឥណ្ឌា ហើយការឈប់សំចតនៅកម្ពុជា គឺជាកម្មវិធីចុងក្រោយបង្អស់ ។ នេះជាទស្សនកិច្ចលើកទីមួយរបស់គណៈប្រតិភូជើងទឹកជប៉ុន ក្រោយពីកងកម្លាំងនេះបានចូលរួមក្នុងសកម្មភាពអ៊ុនតាក់កាលពីឆ្នាំ ១៩៩២-១៩៩៣ ។

នៅក្នុងឆ្នាំ២០០៩នេះ មាននាវាថៃចំនួន ០៥គ្រឿង នាវាបារាំង ០១គ្រឿង និងនាវាអូស្ត្រាលី ០១គ្រឿង បានចូលឈប់សំចតនៅកំពង់ផែក្រុងព្រះសីហនុដើម្បីធ្វើទស្សនកិច្ច ។/

## ក្រសួងព័ត៌មានណែនាំអ្នកកាសែត
## ឱ្យបញ្ឈប់យកគំរូប័ណ្ណសារព័ត៌មានមកបំពាក់លើយានយន្ត

*AKP ភ្នំពេញ*

ចុងសប្តាហ៍កន្លងមកនេះ ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានចេញសេចក្តីណែនាំដល់អ្នកកាសែតជាតិ និងអន្តរជាតិ ដែលមានខ្លឹមសារថា ៖

រយៈពេលកន្លងមកនេះ ក្រសួងព័ត៌មានបានសង្កេតឃើញថា អ្នកកាសែតជាតិ និងអ្នកកាសែតអន្តរជាតិ ដែលកំពុងបំពេញបេសកកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងបានប្រកាន់ខ្ជាប់នូវភាពថ្លៃថ្នូរ មានសីលធម៌ស្អាតស្អំ គោរពវិជ្ជាជីវៈបានត្រឹមត្រូវ ហើយបានប្រើប្រាស់ប្រកបដោយភាពទទួលខុសត្រូវ និងមានប្រសិទ្ធភាពនូវប័ណ្ណសារព័ត៌មានដែលក្រសួងព័ត៌មានបានផ្តល់ជូន ។

ជាមួយគ្នានោះ ក្រសួងព័ត៌មានក៏បានសង្កេតឃើញផងដែរ នូវការអនុវត្តខុសឆ្គងរបស់អ្នកកាសែតយើងក្នុងការប្រើប្រាស់ប័ណ្ណនេះ ជាពិសេសទៅទៀតនោះ មានអ្នកកាសែតយើងខ្លះបានយកជាគំរូប័ណ្ណនេះទៅបំពាក់នៅលើទោចក្រយានយន្ត និងរថយន្តរបស់ខ្លួនមានលក្ខណៈជាផ្លាកសម្គាល់យានយន្ត ដែលមិនមែនជាសមត្ថកិច្ចរបស់ក្រសួងព័ត៌មានផ្តល់ជូន ហើយក្រសួងព័ត៌មានក៏ពុំធ្លាប់បានផ្តល់នូវផ្លាកសម្គាល់យានយន្តប្រភេទនោះឡើយ ។

អាស្រ័យហេតុនេះ ក្រសួងព័ត៌មាន សូមធ្វើការណែនាំដល់អ្នកកាសែតជាតិ និងអន្តរជាតិ ដែលបានប្រព្រឹត្តនូវកំហុសឆ្គងដូចបានរៀបរាប់ខាងលើនេះ សូមបញ្ឈប់ជាបន្ទាន់ នូវសកម្មភាពរបស់ខ្លួន ហើយ

សូមអំពាវនាវដល់គ្រប់អង្គភាពមានសមត្ថកិច្ចចាត់ការនូវទង្វើទាំងនោះតាមការគួរ ។/

## វគ្គបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រ
## និងការធ្វើផែនការ ការចុះត្រួតពិនិត្យ និងវាយតម្លៃគំរោង

*លោក សួស សិរិត AKP ភ្នំពេញ*

ក្រសួងកិច្ចការនារីសហការឧបត្ថម្ភដោយអង្គការពលកម្មអន្តរជាតិ ( ILO ) នាព្រឹកថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៩នេះ នៅសណ្ឋាគារកាំបូឌីយ៉ាណាភ្នំពេញ បានបើកវគ្គបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រដល់គ្រូបង្គោលចំនួន ៣៧នាក់ ដែលមកពីក្រសួងពាក់ព័ន្ធ ៣ គឺក្រសួងកិច្ចការនារី ក្រសួងការងារ និងក្រសួងសង្គមកិច្ច ។

មានប្រសាសន៍ក្នុងឱកាសបើកវគ្គនេះ លោកជំទាវ កេត សំអាត អគ្គនាយកដ្ឋានសមភាពយេនឌ័រ បានបញ្ជាក់ថា បញ្ហាសំខាន់តើធ្វើដូចម្តេចដើម្បីកែលំអវិសមភាពយេនឌ័រនៅលើគ្រប់វិស័យ ដើម្បីផ្តល់ឱ្យស្ត្រីនូវជំនាញ និងស្ថានភាពចាំបាច់ សម្រាប់ស្ត្រីមានឱកាសចូលរួមក្នុងសង្គមទំនើបបច្ចុប្បន្នឈរលើមូលដ្ឋានសិទ្ធិពេញលេញ និងល័ក្ខខ័ណ្ឌការងារសមស្របដោយគុណភាព ។

លោកជំទាវបានបន្តទៀតថា ការបញ្ជ្រាបយេនឌ័រ និងការធ្វើផែនការជាផ្នែកមួយនៃផែនការនារីរតនៈទី២ដែលទទួលស្គាល់ដោយគោលនយោបាយ និងកម្មវិធីរាជរដ្ឋាភិបាលដែលត្រូវបានបញ្ចូលបញ្ហាយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីថ្នាក់ជាតិដោយប្រើប្រាស់មូលដ្ឋានយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។ យុទ្ធសាស្ត្រនេះបានផ្តល់ និងទទួលស្គាល់ថា ស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ និងផ្តល់អាទិភាពលើការលើកកំពស់តួនាទី និងកសាងសមត្ថភាពរបស់ស្ត្រី សំដៅកែប្រែអាកប្បកិរិយាក្នុងសង្គម និងការធានាក្នុងសិទ្ធិរបស់ស្ត្រីក្នុងការចូលរួម និងទទួលផលស្មើភាពពីការអភិវឌ្ឍន៍ជាតិ ។

លោក Takeo Hayaki ប្រធានប្រឹក្សាបច្ចេកទេសអង្គការពលកម្មអន្តរជាតិជប៉ុន បានបញ្ជាក់ពីគោលបំណងនៃវគ្គបណ្តុះណ្តាលដែលមានរយៈពេល ៥ថ្ងៃនេះ ថា ដើម្បីឱ្យសិក្ខាកាមបានស្វែងយល់អំពីមធ្យោបាយផ្សេងៗ បញ្ចូលទស្សនៈយេនឌ័រទៅក្នុងការងារ និងជីវិត ដើម្បីពន្យល់អំពីការធ្វើផែនការ ការចុះត្រួតពិនិត្យតាមដាន និងវាយតម្លៃគំរោងដោយមានការចូលរួម ហើយនិងចេះធ្វើផែនការ ដើម្បីអនុវត្តបញ្ហានេះទៅក្នុងការងាររបស់គេ ពន្យល់អំពីដំណើរការនៃវគ្គបណ្តុះបណ្តាល និងកសាងវគ្គធ្វើផែនការ និងដើម្បីពន្យល់អំពីការកសាងសមាគម និងពន្យល់អំពីសារៈសំខាន់ នៃការកសាងសមាគមនេះទៅក្រុមគោលដៅរបស់គេ ។/

# ក្រុងព្រះសីហនុបញ្ចប់ការងារធ្វើស្រែវស្សា

*លោក ស្វាយ កេតថាណា AKP ក្រុងព្រះសីហនុ*

មកទល់ចុងសប្ដាហ៍ទី១ ខែកញ្ញា ២០០៩នេះ ក្រុងព្រះសីហនុបានបញ្ចប់ការងារស្ទូងដកស្រូវរដូវវស្សាបានជាស្ថាពរអស់ផ្ទៃដីដែលមាន ។

លោក អ៊ឹង សំអុល ប្រធានការិយាល័យកសិកម្ម ខ័ណ្ឌព្រៃនប់ បានប្រាប់ AKP ថា ៖ នៅរដូវវស្សាឆ្នាំ២០០៩នេះ ទឹកភ្លៀងបានធ្លាក់រហូតចាប់តាំងពីដើមខែឧសភាមកទល់ខែកញ្ញា និងកំពុងតែធ្លាក់ជាបន្តបន្ទាប់ទៀត ដែលធ្វើឱ្យមានទឹកដក់ពេញស្រែបង្កលក្ខណៈងាយស្រួលដល់ការងារស្ទូងដកស្រូវវស្សា ។ ក្រុងព្រះសីហនុ មានតែខ័ណ្ឌព្រៃនប់មួយគត់ ដែលមានផ្ទៃដីធ្វើស្រែវស្សា មកទល់ថ្ងៃទី៨ សីហា ឆ្នាំ ២០០៩នេះ សង្កាត់ទាំង១៤របស់ខ័ណ្ឌព្រៃនប់ សំរេចស្ទូងស្រូវបាន ១២.០២០ហិកតា គឺលើសផែនការ ២០ហិកតា ។

ក្នុងចំណោមសង្កាត់ទាំង ១៤ សង្កាត់ជើងគោ មានផ្ទៃដីធ្វើស្រែច្រើនជាងគេ គឺមានផ្ទៃដី ១.១០០ហិកតា ដែលធ្វើស្រែបាន ១០០% លើផ្ទៃដី សង្កាត់ព្រៃនប់ មានផ្ទៃដី ៩០០ហិកតា ដែលធ្វើស្រែបាន ១០០% ដែរ ។

លោកប្រធានការិយាល័យកសិកម្មខ័ណ្ឌព្រៃនប់ ក៏បានបញ្ជាក់បន្ថែមថាៈ មន្ត្រីជំនាញក្សេត្រសាស្ត្រខ័ណ្ឌ សហការជាមួយមន្ទីរកសិកម្មក្រុង ក៏បានយកចិត្តទុកដាក់ជាប្រចាំក្នុងការចុះត្រួតពិនិត្យសភាពការណ៍ធ្វើស្រែរបស់កសិករ ដើម្បីការពារខ្លាចមានគ្រោះធម្មជាតិណាមួយកើតឡើង ដូចជាទឹកភ្លៀង បាក់ទំនប់ទឹកហូរចូលពីសមុទ្រ និងសត្វល្អិតបំផ្លាញ ។ ល ។

មន្ត្រីជំនាញកសិកម្ម ដែលបានសហការជាមួយមន្ត្រីធនធានទឹក ធ្វើការត្រួតពិនិត្យជាប្រចាំទំនប់ការពារទឹកប្រៃ ដើម្បីមានវិធានការបើកទឹកចេញនៅពេលជំនន់ទឹកភ្លៀង និងបិទទឹកវិញនៅពេលខ្សោយទឹកភ្លៀង ធ្វើយ៉ាងណាឱ្យមានទឹកល្មមក្នុងស្រែអាចចិញ្ចឹមសន្ទូងបាន ។ ប្រសិនបើមានទឹកគ្រប់គ្រាន់រហូតដល់ចុងរដូវនោះ ស្រូវទាំង១៤សង្កាត់របស់ខ័ណ្ឌព្រៃនប់ អាចកើនទិន្នផល ដែលអាចសំរួលដល់ជីវភាពកសិករបានយ៉ាងល្អប្រសើរ ។

ឆ្នាំ២០០៨កន្លងមក ទូទាំងខ័ណ្ឌព្រៃនប់ សំរេចធ្វើស្រែបាន ១១,៩៣១ហិកតា និងទទួលទិន្នផល ២តោនកន្លះក្នុងមួយហិកតា ។/